WORLD ASSOCIATION FOR SEXUAL HEALTH

# សេចក្តីប្រកាសនៃសិទ្ធិផ្លូវភេទ

**ដើម្បីទទួលស្គាល់ថា សិទ្ធិនៃការរួមភេទ មានសារសំខាន់សម្រាប់ការសម្រេចបាននូវសុខភាពផ្លូវភេទដែលទទួលបានខ្ពស់បំផុត សមាគមពិភពលោកសម្រាប់សុខភាពផ្លូវភេទ** :

**ថ្លែងថាសិទ្ធិ**នៃការរួមភេទ ត្រូវបានរាប់បញ្ចូលជាសិទ្ធិមនុស្សជាសកលដែលត្រូវបានទទួលស្គាល់ក្នុងឯកសារសិទ្ធិមនុស្ស ថ្នាក់តំបន់ ថ្នាក់ជាតិនិងអន្តរជាតិ រដ្ឋធម្មនុញ្ញនិងច្បាប់ជាតិ គោលការណ៍និងស្តង់ដាសិទ្ធិមនុស្ស និងចំណេះដឹងវិទ្យាសាស្ត្រពាក់ព័ន្ធនឹងសុខភាពផ្លូវភេទ និងការរួមភេទរបស់មនុស្ស។

**អះអាងជាថ្មីថា** ការរួមភេទជាផ្នែកមួយយ៉ាងសំខាន់នៃជីវិតរបស់មនុស្ស រាប់បញ្ចូលទាំង ភេទ មុខងារ និង អត្តសញ្ញាណយេនឌ័រ និន្នាការផ្លូវភេទ(Sexual orientation) ចំណង់ផ្លូវភេទ សេចក្តីរីករាយ ភាពស្និទ្ធស្នាល និង ការបន្តពូជ។ ការរួមភេទ ត្រូវបានជួបប្រទះ និងបញ្ចេញនៅក្នុងគំនិត ការនឹកឃើញ ចំណង់ ជំនឿ អាកប្បកិរិយា តម្លៃ ទង្វើ ការអនុវត្តន៍ តួនាទី និងទំនាក់ទំនង ។ ខណៈពេលដែលការរួមភេទអាចរាប់បញ្ចូលចំណុចទាំងអស់នេះ មិនមែនមានន័យថាចំណុចទាំងអស់នេះតែងតែត្រូវបានជួបប្រទះ និងបង្ហាញនោះទេ។ ការរួមភេទត្រូវបានជះឥទ្ធិពលដោយអន្តរកម្មនៃកត្តាជីវសាស្ត្រ រួមមាន រូបរាងកាយ សង្គម សេដ្ឋិច្ច នយោបាយ វប្បធមិ ច្បាប់ ប្រវត្តិសាស្ត្រ សាសនា និងស្មារតី។

**ទទួលស្គាល់ថា** ការរួមភេទគឺជាប្រភពមួយ នៃភាពរីករាយ និង សុខមាលភាព ហើយថែមទាំងរួមចំណែកដល់ការបំពេញនូវចំណង់ទាំងឡាយឲ្យពេញលេញ និងពេញចិត្ត។

**អះអាងជាថ្មីថា** សុខភាពផ្លូវភេទ គឺជាសភាពមួយនៃរូបរាងកាយ អារម្មណ៍ ផ្លូវចិត្ត និងសុខុមាលភាពសង្គមក្នុងទំនាក់ទំនងផ្លូវភេទ វាមិនមែនគ្រាន់ជាការអវត្តមាននៃជំងឺ បញ្ហា បាត់បង់មុខងារ ឬភាពទន់ខ្សោយនោះទេ។ សុខភាពផ្លូវភេទ តម្រូវឱ្យមានវិធីសាស្ត្រវិជ្ជមាន និងមានការគោរពចំពោះការរួមភេទ និងទំនាក់ទំនងផ្លូវភេទ ក៏ដូចជាលទ្ធភាពរួមភេទដោយរីករាយ និងមានសុវត្ថិភាព ដោយគ្មានការបង្ខិតបង្ខំ ការរើសអើង និង គ្មានអំពើហឹង្សា។

**អះអាងជាថ្មីថា** សុខភាពផ្លូវភេទមិនអាចឲ្យនិយមន័យបានច្បាស់ និងចាប់ផ្តើមដំណើរការដោយគ្មានការយោគយល់ពីអារម្មណ៍នៃការរួមភេទនោះទេ។

**អះអាងជាថ្មីថា** សម្រាប់សុខភាពផ្លូវភេទក្នុងការសម្រេចបាន និងថែទាំ សិទ្ធិនៃការរួមភេទរបស់មនុស្សគ្រប់រូប ត្រូវតែទទួលបានការគោរព ការការពារ និងការបំពេញឲ្យពេញលេញ។

**ទទួលស្គាល់ថា** សិទ្ធិនៃការរួមភេទ គឺអាស្រ័យទៅលើសេរីភាពជាមួយសេចក្តីថ្លៃថ្នូរ និងគុណតំលៃរបស់មនុស្សម្នាក់ៗ ថែមទាំងការប្តេជ្ញាក្នុងការការពារពីគ្រោះថ្នាក់ដែលអាចកើតមានឡើង។

**ថ្លែងថា** ភាពស្មើគ្នា និងការមិនរើសអើង គឺជាគ្រឹះនៃការការពារសិទ្ធិមនុស្ស និងការផ្សព្វផ្សាយ រួមទាំងការហាមឃាត់នៃការបែងចែក លើកលែងតែទៅលើមូលដ្ឋាននៃ ពូជអំបូរ ជាតិសាសន៍  ពណ៌សម្បុរ ភេទ ភាសា សាសនា នយោបាយ ឬ ការយល់ឃើញដទៃទៀត ដើមកំណើតជាតិសាសន៍ ឬ សង្គម ទ្រព្យសម្បត្តិ ឬ ស្ថានភាពដទៃទៀត រួមមាន ពិការភាព អាយុ សញ្ជាតិ ស្ថានភាពគ្រួសារ និន្នាការផ្លូវភេទ **(sexual orientation)** អត្តសញ្ញាណយេនឌ័រ ស្ថានភាពសុខភាព កន្លែងរស់នៅ សេដ្ឋកិច្ច និង ស្ថានភាព សង្គម។

**ទទួលស្គាល់ថា** និន្នាការផ្លូវភេទរបស់មនុស្ស អត្តសញ្ញាណយេនឌ័រ ការបង្ហាញពីអារម្មណ៍ និងភាពខុសគ្នានៃរូបរាងកាយ តម្រូវឲ្យមានការការពារសិទ្ធិត្រឹមត្រូវ។

**ទទួលស្គាល់ថា** អំពើហឹង្សាគ្រប់រូបភាពដូចជា ការបំពាន ការរើសអើង ការឃុំឃាំង និងការមាក់ងាយ គឺជាការរំលោភសិទ្ធិមនុស្ស និងប៉ះពាល់ទៅលើសុខុមាលភាពរបស់មនុស្ស គ្រួសារ និងសហគមន៍។

**បញ្ជាក់ថា** កាតព្វកិច្ចក្នុងការគោរព ការពារ និងធ្វើឲ្យមានសិទ្ធិពេញលេញ នូវការអនុវត្តន៍ទៅលើសិទ្ធិសេរីភាពនៃការរួមភេទ។

**បញ្ជាក់ថា** សិទ្ធិនៃការរួមភេទ ការពារសិទ្ធិមនុស្សទាំងអស់ដើម្បីបំពេញ និងបង្ហាញពីអារម្មណ៍ផ្លូវភេទ និងរួមភេទដោយសេចក្តីសុខ និងពេញចិត្ត អាស្រ័យលើសិទ្ធិអ្នកដទៃ ។

**សិទ្ធិក្នុងការរួមភេទ គឺជាសិទ្ធិមនុស្សទាក់ទងទៅនឹងផ្លូវភេទ** :

### 1. សិទ្ធិទទួលបានភាពស្មើគ្នា និងមិនមានការរើសអើង

មនុស្សគ្រប់រូប មានសិទ្ធិក្នុងការទទួលបានសិទ្ធិនៃការរួមភេទទាំងអស់ដែលមានចែងក្នុងសេចក្តីប្រកាសនេះ ដោយគ្មានការបែងចែក ពូជសាសន៍  ពណ៌សម្បុរ ភេទ ភាសា សាសនា នយោបាយ ឬ ការយល់ឃើញដទៃទៀត ដើមកំណើត ឬ សង្គម ទ្រព្យសម្បត្តិ ឬ ស្ថានភាពដទៃទៀត រាប់បញ្ចូលទាំងពិការភាព អាយុ សញ្ជាតិ ស្ថានភាពគ្រួសារ និន្នាការផ្លូវភេទ អត្តសញ្ញាណយេនឌ័រ ស្ថានភាពសុខភាព កន្លែងរស់នៅ សេដ្ឋកិច្ច និង ស្ថានភាពសង្គម។

### 2. សិទ្ធិរស់រានមានជីវិត សិទ្ធិសេរីភាព និងសន្តិសុខរបស់មនុស្ស

មនុស្សគ្រប់រូបមានសិទ្ធិ រស់រានមានជីវិត សិទ្ធិសេរីភាព និងសន្តិសុខដែលមិនអាចត្រូវបានគំរាមកំហែងតាមអំពើចិត្ត ត្រូវបានកម្រិត ឬ ឆ្ងាយពីមូលហេតុពាក់ព័ន្ធនឹងផ្លូវភេទ។ ទាំងនេះរួមមាន និន្នាការផ្លូវភេទ ឥរិយាបថ និងការព្រមព្រៀងរួមភេទ ការបញ្ចេញមតិ ឬ ដោយការផ្តល់នូវសេវាផ្សេងៗ ដែលទាក់ទងទៅនឹងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។

### 3. សិទ្ធិស្វ័យភាពនិងបូរណភាពរាងកាយ

មនុស្សគ្រប់រូបមានសិទ្ធិក្នុងការគ្រប់គ្រងនិងការសម្រេចចិត្តដោយសេរីលើបញ្ហាដែលពាក់ព័ន្ធនឹងផ្លូវភេទ និងរាងកាយរបស់ពួកគេ។ សិទ្ធិទាំងនោះរួមមាន ជម្រើសនៃឥរិយាបថរួមភេទ ការអនុវត្តន៍ ដៃគូ និងទំនាក់ទំនងនៃការរួមភេទ អាស្រ័យលើសិទ្ធិបុគ្គលម្នាក់ៗ។ សេរីភាពក្នុងការធ្វើការសម្រេចចិត្តដោយគ្មានលក្ខខណ្ឌ តម្រូវឱ្យមានការយល់ព្រម និងទទួលបានព័ត៌មានជាមុននៅពេលធ្វើតេស្ត អន្តរាគមន៍ ការព្យាបាល ការវះកាត់ ការស្រាវជ្រាវ ផ្សេងៗពាក់ព័ន្ធទៅនឹងផ្លូវភេទ។

4. **សិទ្ធិគ្មានអំពើទារុណកម្ម និងភាពឃោរឃៅ អមនុស្សធម៌ ឬ ការព្យាបាលដែលមិនយកចិត្តទុកដាក់ ឬ ទណ្ឌកម្ម**

មនុស្សគ្រប់រូប គួរតែគ្មានអំពើទារុណកម្ម និងភាពឃោរឃៅ អមនុស្សធម៌ ការព្យាបាលដែលមិនយកចិត្តទុកដាក់ ឬ ទណ្ឌកម្មដែលពាក់ព័ន្ធនឹងការរួមភេទ រួមបញ្ចូលទាំង ការអនុវត្តន៍បែបប្រពៃណីដែលបង្កឱ្យមានគ្រោះថ្នាក់ ការវះកាត់ចងបំពង់មេជីវិតដោយបង្ខិតបង្ខំ ការពន្យារកំណើត ការពន្លូតកូន និងការធ្វើទារុណកម្មក្រោមរូបភាពផ្សេងៗទៀតដូចជា អំពើឃោរឃៅ អមនុស្សធម៌ ឬ កំហុសក្នុងការព្យាបាលដោយចេតនាដែលជាមូលហេតុពាក់ព័ន្ធនឹងការរួមភេទរបស់អ្នកណាម្នាក់ និន្នាការផ្លូវភេទ អត្តសញ្ញាណយេនឌ័រ និងការបញ្ចេញមតិ រួមទាំង ភាពចម្រុះនៃរូបរាងកាយផងដែរ។

5. **សិទ្ធិនៃអំពើហឹង្សា និងការបង្ខិតបង្ខំគ្រប់រូបភាព**

មនុស្សគ្រប់រូបគួរតែគ្មានអំពើហឹង្សា និងការបង្ខិតបង្ខំទៅលើផ្លូវភេទ រួមមាន ការរំលោភ ការបំពានផ្លូវភេទ ការយាយីផ្លូវភេទ ការគំរាមគំហែង ការកេងប្រវ័ញ្ច និងទាសករផ្លូវភេទ ការជួញដូរក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ ការធ្វើតេស្តព្រហ្មចារីយ៍ និងអំពើហិង្សាដែលកើតដោយចេតនា និងការតាមដានការប្រព្រឹត្តិនៃអ្នករួមភេទ និន្នាការផ្លូវភេទ អត្តសញ្ញាណយេនឌ័រ និងការបញ្ចេញមតិ រួមទាំងភាពផ្សេងគ្នានៃរូបរាងកាយផងដែរ។

6. **សិទ្ធិជីវិតឯកជន**

មនុស្សគ្រប់រូប មានសិទ្ធិ ជីវិតឯកជន ពាក់ព័ន្ធនឹងការរួមភេទ ជីវិតផ្លូវភេទ និងជម្រើស អាស្រ័យលើបុគ្គល និងទំនាក់ទំនងនៃការព្រមព្រៀងរួមភេទ ព្រមទាំងការអនុវត្តន៍ដោយគ្មានការជ្រៀតជ្រែក និងការឈ្លានពានតាមតែអំពើចិត្តឡើយ។ ដែលនេះរួមបញ្ចូលទាំងសិទ្ធិ ក្នុងការមិនបង្ហាញនូវព័ត៌មានផ្ទាល់ខ្លួនទាក់ទងនឹងការរួមភេទ ដល់អ្នកដទៃផងដែរ។

7. **សិទ្ធិទទួលបាននូវសុខភាពដែលមានស្តង់ដាខ្ពស់បំផុត រួមទាំងសុខភាពផ្លូវភេទ ដោយភាពរីករាយ សេចក្តីពេញចិត្ត និងបទពិសោធរួមភេទដែលមានសុវត្ថិភាព**

មនុស្សគ្រប់រូប មានសិទ្ធិទទួលបាននូវសុខភាពដែលមានកម្រិតខ្ពស់បំផុត និងសុខុមាលភាពនៅក្នុងទំនាក់ទំនងទៅនឹងផ្លូវភេទ ដែលរួមបញ្ចូលទាំងភាពរីករាយ សេចក្តីពេញចិត្ត និងបទពិសោធន៍រួមភេទដែលមានសុវត្ថិភាព។ ទាំងនេះតម្រូវឱ្យមានភាពងាយស្រួល ក្នុងការទទួលបាននូវសេវាសុខភាពដែលមានគុណភាព និងទទួលបាននូវលក្ខខណ្ឌដែលមានអានុភាព និងកំណត់នូវសុខភាពដែលរួមបញ្ចូលទាំងសុខភាពផ្លូវភេទផងដែរ។

8. **សិទ្ធិក្នុងការរីករាយជាមួយនឹងអត្ថប្រយោជន៍នៃការរីកចំរើននៃវិទ្យាសាស្ត្រ និងកម្មវិធីវិទ្យាសាស្ត្រ**

មនុស្សគ្រប់រូប មានសិទ្ធិក្នុងការរីករាយជាមួយនឹងអត្ថប្រយោជន៍នៃការរីកចំរើននៃវិទ្យាសាស្ត្រ និងកម្មវិធីវិទ្យាសាស្ត្រដែលទាក់ទងទៅនឹងការរួមភេទនិងសុខភាពផ្លូវភេទ។

### 9. សិទ្ធិទទួលបានព័ត៌មាន

មនុស្សគ្រប់រូប មានលទ្ធភាពទទួលបាននូវព័ត៌មានវិទ្យាសាស្ត្រដែលត្រឹមត្រូវ និងអាចយល់បាន ពាក់ព័ន្ធនឹងការរួមភេទ សុខភាពផ្លូវភេទ និងសិទ្ធិរួមភេទ តាមរយៈប្រភពជាច្រើន។ ព័ត៌មានបែបនេះមិនគួរត្រូវបានរិះគន់ មិនទទួលស្គាល់ ឬ បំប្លែងដោយចេតនាតាមអំពើចិត្តនោះទេ។

### 10. សិទ្ធិទទួលបាន ការអប់រំ និងការអប់រំផ្លូវភេទយ៉ាងទូលំទូលាយ

មនុស្សគ្រប់រូប មានសិទ្ធិទទួលបាន ការអប់រំ និងការអប់រំផ្លូវភេទយ៉ាងទូលំទូលាយដែលចាំបាច់ត្រូវតែមានអាយុសមរម្យ ត្រឹមត្រូវតាមវិទ្យាសាស្ត្រ សមត្ថកិច្ចផ្នែកវប្បធម៌ និងមានមូលដ្ឋានលើសិទ្ធិមនុស្ស សមភាពយេនឌ័រ និងវិធីសាស្ត្រវិជ្ជមានទៅនឹងការរួមភេទ និងមានអារម្មណ៍រីករាយ។

### 11. សិទ្ធិក្នុងការចាប់ផ្តើម និងបញ្ចប់ចំណងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងផ្សេងៗ អាស្រ័យលើភាពស្មើគ្នា និងការយល់ព្រមទាំងស្រុង

មនុស្សគ្រប់រូប មានសិទ្ធិក្នុងការជ្រើសរើស ថាតើរៀបការ ឬ មិនរៀបការ និងមានការសម្រេចចិត្តដោយសេរី និងពេញលេញ ក្នុងការព្រមព្រៀងចំពោះការរៀបការ ជ្រើសរើសដៃគូ និងទំនាក់ទំនងផ្សេងៗ។ មនុស្សទាំងអស់មានសិទ្ធិស្មើគ្នា ក្នុងការចាប់ផ្តើម និងបញ្ចប់ចំណងអាពាហ៍ពិពាហ៍ បញ្ចប់ដៃគូ និងទំនាក់ទំនងផ្សេងៗ ដោយគ្មានការរើសអើង និងការហាមឃាត់ណាមួយឡើយ។ សិទ្ធិនេះរួមបញ្ចូលទាំង ភាពស្មើគ្នាក្នុងការទទួលបានសុខុមាលភាពសង្គម និងផលប្រយោជន៍ផ្សេងៗទៀត ដោយមិនគិតពីទម្រង់នៃទំនាក់ទំនងនោះឡើយ។

### 12. សិទ្ធិសម្រេចក្នុងការមានកូន ចំនួននកូន គម្លាតនៃការមានកូន និងមានព័ត៌មានក្នុងការសម្រេចចិត្ត

មនុស្សគ្រប់រូប មានសិទ្ធិសម្រេចក្នុងការមានកូន ចំនួនកូន ព្រមទាំងគម្លាតនៃការមានកូនផងដែរ។ ដើម្បី អនុវត្តសិទ្ធនេះ តម្រូវឱ្យមានលក្ខខណ្ឌ ដែលជាអានុភាព និងកំណត់នូវសុខភាពនិងសុខុមាលភាព រួមទាំងសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ទាក់ទងនឹងការមានផ្ទៃពោះ ការពន្យារកំណើត ការមានកូន ការបញ្ចប់ការមានផ្ទៃពោះ និងការទទួលកូនមកចិញ្ចឹម។

### 13. សិទ្ធិសេរីភាពក្នុងការគិត ការយល់ឃើញ និងការបញ្ចេញមតិ

មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការគិត ការយល់ឃើញ និងការបញ្ចេញមតិទាក់ទងនឹងការរួមភេទ និងមានសិទ្ធិបង្ហាញពីការគិតរបស់ពួកគេទាក់ទងនឹងផ្លូវភេទ ឧទាហរណ៍ដូចជា រូបរាង ទំនាក់ទំនង និងឥរិយាបថ ដោយមានការគោរពនូវសិទ្ធិអ្នកដទៃ។

### 14. សិទ្ធិសេរីភាពនៃការសហការនិងការជួបជុំដោយសន្តិវិធី

មនុស្សគ្រប់រូប មានសិទ្ធិ ក្នុងការរៀបចំ សហការ ប្រមូលផ្តុំ បង្ហាញ និងតស៊ូមតិពាក់ព័ន្ធនឹងការរួមភេទ សុខភាពផ្លូវភេទ និងសិទ្ធិរួមភេទ។

### 15. សិទ្ធិចូលរួមក្នុងជីវិតសាធារណៈនិងនយោបាយ

មនុស្សគ្រប់គ្នា មានសិទ្ធិទទួលបានបរិយាកាសមួយ ដែលអនុញ្ញាតឱ្យមានការចូលរួមយ៉ាងសកម្មដោយសេរី និងមានអត្ថន័យ ដែលជាការចូលរួមចំណែកក្នុងសង្គមស៊ីវិល សេដ្ឋកិច្ច សង្គម វប្បធម៌ នយោបាយ និងផ្នែក

ផ្សេងៗទៀតនៃជីវិតមនុស្ស ទាំងថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិជាដើម។ ជាពិសេស មនុស្សទាំងអស់មានសិទ្ធិក្នុងការចូលរួមក្នុងការអភិវឌ្ឍន៍ និងការអនុវត្តន៍នយោបាយដែលកំណត់នូវសុខុមាលភាពរបស់ពួកគេ ដែលរួមបញ្ចូលទាំងការរួមភេទ និងសុខភាពផ្លូវភេទរបស់ពួកគេ។

16. **សិទ្ធិទទួលបាន យុត្តិធម៌ដំណោះស្រាយ និងសំណងផ្លូវចិត្ត**

មនុស្សគ្រប់រូបមានសិទ្ធិទទួលបាន យុត្តិធម៌ ដំណោះស្រាយ និងសំណងផ្លូវចិត្តនៃការរំលោភបំពានលើសិទ្ធិផ្លូវភេទ ។ ហើយវាតម្រូវឱ្យមានភាពមានប្រសិទ្ធភាព ភាពសមស្រប ភាពដែលអាចរកបាន និងការអប់រំដែលសមរម្យ ច្បាប់ តុលាការ និងវិធានការផ្សេងៗ។ ដំណោះស្រាយទាំងនេះ រួមបញ្ចូលទាំងការសងជំងឺចិត្តតាមរយៈសំណង ការប៉ះប៉ូវ ការធ្វើឱ្យមាននិតិសម្បទាឡើងវិញ សេចក្តីពេញចិត្ត ការធានាថាមិនមានការផ្ទៀង-ផ្ទាត់ ឬ សើរើឡើងវិញ។

***

នេះជាការបកប្រែជាផ្លូវការនៃសេចក្តីប្រកាសសិទ្ធិផ្លូវភេទ។ សម្រាប់គោលបំណងផ្នែកច្បាប់ និងបច្ចេកទេស គួរផ្ទៀងផ្ទាត់ជាមួយអត្ថបទជាភាសាអង់គ្លេសផ្លូវការ :
http://www.worldsexology.org/resources/declaration-of-sexual-rights/

សមាគមពិភពលោកសម្រាប់សុខភាពផ្លូវភេទ (WAS) គឺជាក្រុមពហុវិន័យសកល នៃសង្គមវិទ្យាសាស្ត្រ អង្គការក្រៅរដ្ឋាភិបាល និងអ្នកជំនាញ នៅក្នុងវិស័យនៃផ្លូវភេទរបស់មនុស្ស ដែលធ្វើការផ្សព្វផ្សាយសុខភាពផ្លូវភេទពេញមួយជីវិត និងតាមរយៈពិភពលោកដោយ ការអភិវឌ្ឍន៍ ការផ្សព្វផ្សាយ និងការគាំទ្រ ការសិក្សាពីលក្ខណៈនៃភេទរបស់មនុស្ស និងសិទ្ធិផ្លូវភេទ សម្រាប់មនុស្សគ្រប់គ្នា ។ WAS បំពេញនូវគោលបំណងដោយសកម្មភាពតស៊ូមតិ បណ្តាញសម្របសម្រួលនៃការផ្លាស់ប្តូរព័ត៌មាន គំនិត និងបទពិសោធស៍ រួមទាំងឈានចូលមុនតាមបែបវិទ្យាសាស្ត្រអាស្រ័យលើការស្រាវជ្រាវផ្លូវភេទ ការអប់រំផ្លូវភេទ និងការសិក្សាលើការព្យាបាលលក្ខណៈនៃភេទរបស់មនុស្ស ជាមួយការចែកចាយចំណេះដឹង និងជំនាញតាមរយៈសមាជិកក្រុមអ្នកផ្តល់ចំណេះដឹងសហការជាមួយសមាជិកដទៃទៀត។ សេចក្តីប្រកាសរបស់ WAS នៃសិទ្ធិផ្លូវភេទ ត្រូវបានប្រកាសដំបូងនៅសន្និបាតពិភពលោកលើកទី ១៣ នៃការសិក្សាពីលក្ខណៈភេទរបស់មនុស្ស នៅទីក្រុងវ៉ាលិនសៀ ប្រទេសអេស្បាញ ក្នុងឆ្នាំ ១៩៩៧ បន្ទាប់មកក្នុងឆ្នាំ ១៩៩៩ ការកែតម្រូវ ត្រូវបានអនុម័តនៅទីក្រុងហុងកុង ដោយការប្រជុំទូទៅរបស់ WAS បន្ទាប់មកអះអាងសាជាថ្មីក្នុងសេចក្តីប្រកាសរបស់ WAS : សុខភាពផ្លូវផេផភាពផ្លូវភេទសម្រាប់សហស្សវត្ស (២០០៨)។ សេចក្តីប្រកាសដែលត្រូវបានកែតម្រូវនេះត្រូវបានអនុម័តដោយក្រុមប្រឹក្សារបស់ WAS នៅក្នុងខែមីនា ឆ្នាំ ២០១៤។